# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញចុះពិនិត្យ និងពង្រឹងការគ្រប់គ្រងសហគមន៍អ្នកផលិតអំបិល ខេត្តកំពត និងខេត្ត កែប



ដោយសារធាតុអំបិលជាប្រភេទអាហារផ្សំមានជាតិប្រៃ ដែលមនុស្សគ្រប់រូបត្រូវទទួលទានរាល់ថ្ងៃមិនអាចខ្វះបាន ដើម្បីទ្រទ្រង់រាងកាយ និងសុខភាព ។ ម៉្យាងទៀត រាជរដ្ឋាភិបាលក៏បានចាត់ទុកអំបិលជាស្បៀងយុទ្ធសាស្ត្រផងដែរ ទើបកន្លងមក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចផ្តល់ប័ណ្ណកម្មសិទ្ធស្របច្បាប់ឱ្យក្រុមសាមគ្គីផលិតអំបិលតកូនតចៅចំនួន ៣.៥៧៤,៧៦០ ហិចតា ដែលមាន ស.ជ.ណ ភ្ជាប់មកជាមួយ ចាប់តាំងពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០០៨ ។ ដើម្បីស្វែងយល់ពីការគ្រប់គ្រងរបស់សហគមន៍អ្នកផលិតអំបិល ខេត្តកំពត និងខេត្ត កែប នៅព្រឹកថ្ងៃទី៣០ ខែ មីនា ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឯកឧត្តម **កែន សត្ថា** អភិបាលនៃគណៈអភិបាល ខេត្តកែប ឯកឧត្តម **អ៊ុំង ម៉េងហួរ** អភិបាលរងខេត្តកំពត រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួង បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិនិត្យស្វែងយល់ពីការគ្រប់គ្រងរបស់សហគមន៍អ្នកផលិតអំបិលខេត្តកំពត និងខេត្ត កែប នៅទីស្នាក់ការសហគមន៍ ស្ថិតនៅក្នុងស្រុកទឹកឈូរ ខេត្តកំពត ។

តាមរបាយការណ៍របស់លោក **ប៊ុន បារាំង** សហប្រធានសហគមន៍អ្នកផលិតអំបិល ខេត្តកំពត និងខេត្តកែប បានបញ្ជាក់ថា: មកដល់បច្ចុប្បន្ននេះ ផ្ទៃដីផលិតអំបិលមានរហូតដល់ ៤.៥៨៨,៦៨ ហិចតា មានសមាជិកកើនឡើងចំនួន១៩៧ ក្រុមសាគ្គី ។ ក្នុងនោះ ខេត្តកំពត មានសមាជិកចំនួន ១៧៤ ក្រុមសាមគ្គី មានផ្ទៃដីចំនួន ៣.៥៨៧,២៤ ហិចតា និងខេត្តកែប មាន២៣ក្រុមសាមគ្គី មានផ្ទៃដីចំនួន ១.០០១,៤៤ ហិចតា ចែកចេញជា ០៧មណ្ឌលមាន :មណ្ឌលបឹងទូក-មណ្ឌលត្រើយកោះ-មណ្ឌលបឹងរូងទី១-មណ្ឌលបឹងរូងទី២-មណ្ឌលសេះស-មណ្ឌលកែប និងមណ្ឌលកំពង់ត្រាច ស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ ចាប់ពីឃុំបឹងទូក ស្រុកទឹកឈូរ រហូតដល់ភូមិលក ឃុំឫស្សី ស្រុកខាងលិច ស្រុកកំពង់ត្រាច ជាប់ព្រំដែនប្រទេសវៀតណាម ។ បុគ្គលិកសហគមន៍ អ្នកផលិតអំបិលបម្រើ

ការផ្ទាល់មានចំនួន ៧៨ នាក់ ។ ក្រុមប្រឹក្សាភិបាលមានចំនួន១៥រូប គណៈកម្មាធិការប្រតិបត្តិ ចំនួន០៥រូប និងទីប្រឹក្សាចំនួន ០៣រូប កម្មករអណ្តែតចំនួន ៤.៥៨៨ នាក់ និងអ្នកបច្ចេកទេសផលិត(មេការ) ចំនួន២០០នាក់ សរុបចំនួន ៤.៨៦៦ នាក់។ របាយការណ៍ក៏ បានបញ្ជាក់ផងដែរថាៈផលិតកម្មអំបិលមានការប្រែប្រួលជារៀងរាល់ឆ្នាំទៅតាមអាកាសធាតុ និងបានលើកឡើងនូវភាពប្រឈមនានាផងដែរ។





មានប្រសាសន៍ នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងរបស់សហគមន៍ ដែលបានគោរពនូវលក្ខន្តិកៈរបស់ខ្លួន ហើយអនុវត្តនូវគោលការណ៍ ផែនការវិលជុំច្បាស់លាស់ ចេះរួបរួមសាមគ្គីគ្នា ជួយដោះទុក្ខធុរៈគ្នា គោរពសិទ្ធិទៅវិញទៅមក ទើបសហគមន៍សម្រេចបានលទ្ធផលល្អៗ ជាពិសេសសម្រេចបាននូវការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិលជាសកលបាន១០០% តាមអនុក្រឹត្យលេខ៦៩ អ ន ក្រ ប ក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថាៈ ដើម្បីឆ្លើយតបចំពោះការយកចិត្តទុកដាក់ ការផ្តល់ទំនុកចិត្ត និងការលើកទឹកចិត្តពីប្រមុខរាជរដ្ឋាភិបាល គឺ **សម្តេច តេជោ ហ៊ុន សែន** ដើម្បីបន្តនិរន្តរភាពផលិតកម្មអំបិលក្នុងសហគមន៍តកូនតចៅ និងធានាបានការផ្គត់ផ្គង់ក្នុងស្រុក កាត់បន្ថយការនាំចូលអំបិលពីខាងក្រៅ គឺទាំងថ្នាក់ក្រសួង ដៃគូពាក់ព័ន្ធ និងសហគមន៍ត្រូវរួមគ្នាដោះស្រាយភាពប្រឈមទាំងឡាយ ដែលសហគមន៍ជួបប្រទះ ដោយឯកឧត្តម បានផ្តល់អនុសាសន៍ និងការដោះស្រាយជាក់ស្តែងមួយចំនួន ដូចជាៈបង្កើតគណៈកម្មការអន្តរក្រសួងឡើងវិញ ដើម្បីកំណត់ទីតាំងដីស្រែអំបិលពិតប្រាកដ ធ្វើប្លង់កម្មសិទ្ធិជូនសហគមន៍ និងដោះស្រាយដីដែលជាន់សមត្ថកិច្ចគ្រប់គ្រងរបស់ខ័ណ្ឌរដ្ឋបាលជលផល-រក្សា និងពិនិត្យលទ្ធភាពពង្រីកផ្ទៃដី ដោយទប់ស្កាត់ការសុំប្តូរប្រភេទដីធ្វើអាជីវកម្មទៅមុខសញ្ញាផ្សេងៗ-ពិនិត្យលទ្ធភាពតាមផ្លូវច្បាប់ តើគួរបង្វែរពីការបង់ពន្ធស៊ុយសារ៉ែអំបិល ទៅជាការចុះបញ្ជីសហគ្រាសរឺសិប្បកម្ម រឺយ៉ាណា?-ធ្វើយ៉ាងណាឱ្យអ្នកផលិតអំបិលទាំងអស់ចូលក្រោមឆ័ត្រសហគមន៍តែមួយ-រិះរកវិធី និងបច្ចេកទេសថ្មីៗ ដើម្បីបង្កើន គុណភាព ផលិតភាព សោភ័ណ្ឌភាព សុវត្ថិភាព និងអនាម័យ ជាពិសេសអំបិលដែលត្រូវយកមកបរិភោគត្រូវរក្សាឱ្យមានជាតិអ៊ីយ៉ូដ ១០០% ជានិច្ច ។

បន្ទាប់មក នៅរសៀលថ្ងៃដដែល ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** គណៈអធិបតី និងសមាជិកអង្គប្រជុំទាំងអស់ បានអញ្ជើញចុះពិនិត្យជាក់ស្តែងពីដំណើរការផលិតកម្មអំបិល នៅលើវាលស្រែអំបិលដ៏ធំល្វឹងល្វើយ ដោយជាដំបូងចុះទស្សនៈកិច្ចក្រុមហ៊ុន **Asia Salt** ដែលជាក្រុមហ៊ុនផលិតអំបិលមកពីប្រទេសកូរ៉េខាងត្បូង ផលិតតាមបច្ចេកទេសទំនើប ដោយប្រើជាតិផ្លាស់ស្ទីកពណ៌ខ្មៅសម្រាប់ទ្រាប់កំណាកអំបិល និងអនុវត្តផែនការវិលជុំច្បាស់លាស់ ធ្វើឱ្យផលិតផលអំបិលចេញមកមានលក្ខណៈស្អាត មិនជាប់ដី និងអនាម័យ ។ ការផលិតនេះគឺលើវាលស្រែសាកល្បងប្រមាណជាង១៧០ ហិចតា របស់សហគមន៍ ដើម្បីទុកជាគម្រូសម្រាប់សហគមន៍ពិចារណាអនុវត្តតាមនាថ្ងៃខាងមុខ ហើយបច្ចេកទេសនេះក៏ត្រូវទទួលការកោតសរសើរពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងប្រតិភូអមដំណើរផងដែរ ។ បន្ទាប់មក គណៈប្រតិភូទាំងអស់បានបន្តដំណើរចុះពិនិត្យការកាយអំបិលរបស់កម្មករអំបិលលើស្រែអំបិលរបស់សហគមន៍ ដែលធ្លាប់ធ្វើតាមប្រពៃណីជាយូរលង់មកហើយ ព្រមទាំងធ្វើការសំណេះសំណាល សាកសួរសុខទុក្ខ និងចែកជូនថវិកាមួយចំនួន មុននឹងគណៈប្រតិភូ ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** អញ្ជើញបន្តចុះពិនិត្យ ក្នុងសិប្បកម្មកែច្នៃអំបិលមួយឈ្មោះ **នួន ហួន** ដែលមានទីតាំងជិតវាលស្រែអំបិលដែរ ដែលនៅទីនោះ ឃើញមានកម្មករកំពុងមមាញឹក បញ្ចាគ្រឿងម៉ាស៊ីន ច្រក និងដេរបញ្ចូលបាវទម្ងន់៥០គ.ក្រ រួចដឹកជញ្ជូនគរទុកមួយដុំ មុនដាក់ចរាចរលើទីផ្សារ ។







